**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: ០០៦ សហវ

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៧

## សេចក្តីសំរេច
## ស្តីពី
## ការកែសម្រួល និងបំពេញបន្ថែមនូវមុខងារ និងភារកិច្ចរបស់ការិយាល័យគយ និងរដ្ឋាករអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ

៚ * ៚

អនុលោមតាមប្រកាសលេខ ៩២០ សហវ គរ ប្រក ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៣ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ទីចាត់ការគយ និងរដ្ឋាករ និងដើម្បីឆ្លើយតបទៅនឹងសំណូមពរការងារចាំបាច់របស់ទីចាត់ការគយ និងរដ្ឋាករ ក្នុងគោលបំណងរក្សានូវតុល្យភាពនៃតម្រូវការនៃការបង្កើនប្រសិទ្ធភាពការងារគយ និងរដ្ឋាករ និងការបន្តអនុវត្តកិច្ចសម្រួលពាណិជ្ជកម្មនោះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សំរេចកែសម្រួល និងបំពេញបន្ថែមជាបណ្តោះអាសន្ននូវមុខងារ និងភារកិច្ចរបស់ការិយាល័យគយ និងរដ្ឋាករអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ដូចខាងក្រោម :

១- ប្រគល់មុខងារ និងភារកិច្ចបន្ថែមឱ្យការិយាល័យគយ និងរដ្ឋាករអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ទទួលបន្ទុកគ្រប់គ្រង ត្រួតពិនិត្យដោយផ្ទាល់នូវកិច្ចដំណើរការទីស្នាក់ការគយ និងរដ្ឋាករផ្សេងទៀតតាមអាកាសយានដ្ឋានអន្តរជាតិនានា ក្នុងព្រះរាជាណាចក្រកម្ពុជា។

២- ប្រគល់ភារកិច្ចរៀបចំធ្វើសំណើសុំផ្លាស់ប្តូរមន្ត្រីរាជការគយ និងរដ្ឋាករក្រោមឱវាទ ពីអាកាសយានដ្ឋានអន្តរជាតិមួយទៅអាកាសយានដ្ឋានអន្តរជាតិមួយទៀត តាមរូបភាពវង្វិលជុំ និងតាមសំណូមពរការងារជាក់ស្តែង ដាក់សុំការពិនិត្យ និងសំរេចពីប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជានាយកទីចាត់ការគយ និងរដ្ឋាករ។

៣- ទីចាត់ការគយ និងរដ្ឋាករ ត្រូវចាត់ចែង ផ្សព្វផ្សាយ និងអនុវត្តតាមខ្លឹមសារសេចក្តីសំរេចនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

**ចម្លងជូន :**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- សាលាខេត្ត ក្រុងពាក់ព័ន្ធ
  "ដើម្បីជូនជ្រាប"
- ឯកសារ - កាលប្បវត្តិ